ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែវិច្ឆិកា និងទិសដៅការងារខែធ្នូ ឆ្នាំ២០២៥

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៥ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥

### ១-មុខងារនីតិកម្ម

- សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ (ក.ជ.ប.ព) លើកទី៤ អាណត្តិទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ប្រធាន (ក.ជ.ប.ព) នៅអង្គភាពប្រឆាំងអំពើពុករលួយ។

### ២-មុខងារតំណាង

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា រួមមាន៖

❖ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា៖

▪ សកម្មភាពចូលរួមពិធីផ្សេងៗ៖

• បានអញ្ជើញដង្ហែ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា (៩ វិច្ឆិកា ១៩៥៣ - ៩ វិច្ឆិកា ២០២៥) និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៥ នៅវិមានឯករាជ្យ រាជធានីភ្នំពេញ។

- បានអញ្ជើញដង្ហែ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីពន្លត់ទៀនជ័យនៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ( ៩ វិច្ឆិកា ១៩៥៣ - ៩ វិច្ឆិកា ២០២៥) នាឱកាសប្រារព្ធព្រះរាជពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៥ នៅវិមានឯករាជ្យ រាជធានីភ្នំពេញ។
- បានអញ្ជើញជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស លើកទី៣៣ ឆ្នាំ២០២៥ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ និង
- បន្តតាមដាន និងផ្តល់យោបល់អំពីការវិវត្តសភាពការណ៍នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**

▪ **សកម្មភាពដឹកនាំកិច្ចប្រជុំ៖** បានអញ្ជើញដឹកនាំកិច្ចប្រជុំជាមួយក្រុមទីប្រឹក្សា និងក្រុមជំនួយការខុទ្ទកាល័យ ដើម្បីពិភាក្សាកិច្ចការទូទៅ និងត្រៀមចុះសួរសុខទុក្ខជនភៀសសឹក និងវីរកងទ័ព នៅខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

▪ **បេសកកម្មក្នុងប្រទេស៖** បានចាត់តាំង **ឯកឧត្តម ឡាន់ ឆន** និង**ឯកឧត្តម ជឹម លាវ** សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ចុះជួបសំណេះសំណាល និងដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសាធារណរដ្ឋបារាំង ចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋក្រីក្រ និងកុមារដោយឥតគិតថ្លៃ នៅខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ។

▪ **សកម្មភាពចូលរួមពិធីផ្សេងៗ៖**

- បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញដាក់កម្រងផ្កា និងគោរពវិញ្ញាណក្ខន្ធបុព្វការីជន នៅវិមានឯករាជ្យ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមក្នុងព្រះរាជពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ( ៩ វិច្ឆិកា ១៩៥៣- ៩ វិច្ឆិកា ២០២៥) និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៥ ក្រោមព្រះរាជធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានឯករាជ្យ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមព្រះរាជពិធីពន្លត់ទៀនជ័យ នាឱកាសប្រារព្ធព្រះរាជពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៥ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត

របស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានឯករាជ្យ រាជធានីភ្នំពេញ។

- បានអញ្ជើញជាគណៈអធិបតីក្នុងពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស លើកទី៣៣ ប្រចាំឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមកម្មវិធីបើក និងចូលរួមប្រកួតវាយកូនគោល PRO-AM ក្នុងការប្រកួតកីឡាវាយកូនគោលជើងឯកវឌ្ឍនៈឡេងជិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទសិក្ខាសាលាស្តីពី "ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦" នៅវិមានរដ្ឋសភា។
- បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសចូលកាន់តំណែងរបស់ **ឯកឧត្តម ឌី បញ្ញា** ជាអគ្គលេខាធិការរងព្រឹទ្ធសភា នីតិកាលទី៥ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា និង
- បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តម នុត សាអាន** ប្រធានគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម នៅខណ្ឌចំការមន រាជធានីភ្នំពេញ។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ទឈ្មុនា អនុប្រធានទី២ព្រឹទ្ធសភា៖**

- **សកម្មភាពដឹកនាំកិច្ចប្រជុំ៖**
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំប្រចាំខែវិច្ឆិកា ជាមួយប្រធានគណៈកម្មការទាំង១០ព្រឹទ្ធសភា ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ប្រធានក្រុមសមាជិកាព្រឹទ្ធសភា និងប្រធានគណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា ដើម្បីពិភាក្សាអំពីសំណើអន្តរាគមន៍ទៅថ្នាក់ដឹកនាំព្រឹទ្ធសភារបស់គណៈកម្មការ និងភូមិភាគ និងការរៀបចំផែនការ និងអាទិភាពការងារសម្រាប់ឆ្នាំ២០២៦ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
  - បានអញ្ជើញដឹកនាំប្រជុំគណៈកម្មការពិសេស ដើម្បីពិនិត្យ និងកែសម្រួលសេចក្តីស្នើច្បាប់វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាឱ្យស្របតាមស្មារតីអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា និង
  - បានអញ្ជើញដឹកនាំប្រជុំជាមួយទីប្រឹក្សា ថ្នាក់ដឹកនាំ និងសមាជិកខុទ្ទកាល័យ ប្រចាំខែវិច្ឆិកា និងកំណត់ទិសដៅការងារខែធ្នូ ឆ្នាំ២០២៥ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- **សកម្មភាពចុះមូលដ្ឋាន៖**
  - បានអញ្ជើញជួបសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ សិស្សានុសិស្សនៃសាលាបឋមសិក្សាកោះដាច់ ដោយបាននាំយកទឹកដោះគោ និងសម្ភារសិក្សាមួយចំនួន

ជូនដល់សិស្សានុសិស្សនៃសាលាបឋមសិក្សាកោះដាច់ផងដែរ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និង

- បានអញ្ជើញជួបសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់កោះដាច់ នៅសាលាសង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

▪ **សកម្មភាពចូលរួមពិធីផ្សេងៗ៖**

- បានអញ្ជើញចូលរួមក្នុងព្រះរាជពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា (៩ វិច្ឆិកា ១៩៥៣ - ៩ វិច្ឆិកា ២០២៥) និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៥ ក្រោមព្រះរាជធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានឯករាជ្យ រាជធានីភ្នំពេញ។
- បានញ្ជើញចូលរួមព្រះរាជពិធីពន្លត់ទៀនជ័យ នាឱកាសប្រារព្ធព្រះរាជពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៥ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានឯករាជ្យ រាជធានីភ្នំពេញ និង
- បានអញ្ជើញជាគណៈអធិបតីក្នុងពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស លើកទី៣៣ ប្រចាំឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ។

❖ **សមាជិក សមាជិកាព្រឹទ្ធសភា៖**

▪ បានអញ្ជើញចូលរួមព្រះរាជពិធីបួងសួងចម្រើនសេចក្តីសុខជូន ព្រះរាជាណាចក្រកម្ពុជា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល នៅព្រះបរមរាជវាំង។

▪ បានអញ្ជើញចូលរួមក្នុងព្រះរាជពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា (៩ វិច្ឆិកា ១៩៥៣ - ៩ វិច្ឆិកា ២០២៥) និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៥ ក្រោមព្រះរាជធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានឯករាជ្យ រាជធានីភ្នំពេញ។

▪ បានញ្ជើញចូលរួមព្រះរាជពិធីពន្លត់ទៀនជ័យ នាឱកាសប្រារព្ធព្រះរាជពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៥ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត

របស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានឯករាជ្យ រាជធានីភ្នំពេញ។

- បានអញ្ជើញថ្វាយកម្រងផ្កា គោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ " ព្រះបរមរតនកោដ្ឋ "** នៅមណ្ឌបតម្កល់ព្រះបរមរូប សួនច្បារខាងកើតវិមានឯករាជ្យ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមពិធីអនុស្សាវរីយ៍មហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស លើកទី៣៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមសិក្ខាសាលា ដើម្បីឈ្វេងយល់អំពីការកសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា នៅសាលសន្និសីទបន្ទាយស្រី វិមានរដ្ឋសភា។
- បានអញ្ជើញជាកិត្តិយសក្នុងវេទិកាជាតិស្តីពី "ស្ត្រីក្នុងភាពជាអ្នកដឹកនាំរបស់ស្ត្រី និងក្មេងស្រី ដើម្បីទាំងអស់គ្នា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ។
- បានអញ្ជើញចូលរួមប្រជុំកំពូលព្រះពុទ្ធសាសនាបីប្រទេស កម្ពុជា-ឡាវ-វៀតណាម លើកទី៣ ក្រោមមូលបទ "សុខដុមនីយកម្មព្រះពុទ្ធសាសនា ដើម្បីសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមពិធីសំណេះសំណាលជាមួយសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍នៅទូទាំងប្រទេស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពង់របស់ **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ប្រធានសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ និងជាឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ តាមប្រព័ន្ធវីដេអូ នៅសាលប្រជុំសមាគមនារី រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមប្រជុំគណៈអចិន្ត្រៃយ៍សមាគមនារីកម្ពុជាដើម្បីត្រួតពិនិត្យលើវឌ្ឍនភាពការងារគណៈកម្មការរៀបចំមហាសន្និបាតវិសាមញ្ញសមាគមនារី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ប្រធានសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ និងជាឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៅវិមាន៧មករា។
- បានអញ្ជើញចូលរួមកម្មវិធីចេញផ្សាយរបាយការណ៍ស្តីពី ការតាមដានលើការអនុវត្តអនុសញ្ញាស៊ី-ដ សម្រាប់ឆ្នាំ២០២៣ និង២០២៤ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។

- បានអញ្ជើញចូលរួមពិធីបើកនៃកម្មវិធីតាំងពិព័រណ៍ស្តីពី "ទម្លាយភាពស្ងៀមស្ងាត់នៃអំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម" នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។
- បានអញ្ជើញចូលរួមប្រជុំការងារ ដើម្បីពិភាក្សាត្រៀមរៀបចំប្រជុំតាមប្រព័ន្ធនិម្មិត (Online) លើការងារប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតសកល ក្រោមអធិបតីភាពរបស់ **ឯកឧត្តម យស ផានីត្តា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា និងជាប្រធានក្រុមបណ្តាញសមាជិកសភាប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតសកល នៅសាលប្រជុំគណៈកម្មការទី២ វិមានព្រឹទ្ធសភា។
- បានអញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកព្រះរាជអំណោយ ថ្នាំពេទ្យ គ្រឿងឧបភោគ បរិភោគ សម្ភារប្រើប្រាស់ ចំនួន២លើក ជូនវីរកងទ័ពជួរមុខប្រចាំទិស ខេត្តព្រះវិហារ នៅទីបញ្ជាការកងពលតូចអន្តរាគមន៍លេខ៩ នៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។
- បានអញ្ជើញទទួលជំនួយមនុស្សធម៌លើកទី១៣ និងលើកទី១៤ របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ រួមមាន ឧបករណ៍វេជ្ជសាស្ត្រ ឱសថ និងសម្ភារប្រើប្រាស់ប្រចាំថ្ងៃផ្សេងៗ នៅវិមានព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌នៃសាធារណរដ្ឋបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា(AMH) ចុះពិនិត្យ និងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋ និងប្រជាពលរដ្ឋក្រៀសសឹកដោយឥតគិតថ្លៃ នៅខេត្តបន្ទាយមានជ័យ ខេត្តតាកែវ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងរាជធានីភ្នំពេញ និង

- ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាលសាកសួរសុខទុក្ខប្រជាពលរដ្ឋ និងជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀននាយប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធានមណ្ឌលសុខភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ សន្តិសុខ សណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា **ចំនួន១០០លើក** ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ **ចំនួន១០៥លើក**។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖

- បានអញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**

នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញជាអធិបតីក្នុងពិធីអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស លើកទី៣៣ ឆ្នាំ២០២៥ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ។

- បានអញ្ជើញចូលរួមព្រះរាជពិធីពន្លត់ទៀនជ័យ នាឱកាសប្រារព្ធព្រះរាជពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៥ នៅវិមានឯករាជ្យ រាជធានីភ្នំពេញ។
- បានអញ្ជើញជួបសំណេះសំណាលជាមួយនិវត្តជន និងមន្ត្រីរាជការវ័យចំណាស់នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា និង
- បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព **លោក យឿង យ៉ា** អនុប្រធានការិយាល័យនៃជំនួយការអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងកុមារា **យិន ធនិន** កូនប្រុសបង្កើត នៅខេត្តតាកែវ។

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម អោក ប៉ូរ៉ា** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញថ្វាយកម្រងផ្កា គោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ " ព្រះបរមរតនកោដ្ឋ "** និងបានចូលរួមព្រះរាជពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៥ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា នៅមណ្ឌបតម្កល់ព្រះបរមរូប សួនច្បារខាងកើតវិមានឯករាជ្យ រាជធានីភ្នំពេញ។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការស្តីទីព្រឹទ្ធសភា **ឯកឧត្តម អោក ប៉ូរ៉ា** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីប្រកាសចូលកាន់តំណែង**ឯកឧត្តម ឌី បញ្ញា** អគ្គលេខាធិការរងព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា៖

- បានអញ្ជើញអមដំណើរ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយជូនកងទ័ពសមរភូមិមុខ និងគ្រួសារយុទ្ធជន នៅខេត្តឧត្តរមានជ័យ និងខេត្តបាត់ដំបង និង
- បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងចូលរួមពិធីផ្សេងៗ ចំនួន៥លើក។

❖ **ឯកឧត្តម អោក ប៉ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា៖

- បានអញ្ជើញចូលរួមជាកិត្តិយសជាមួយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌ នៃសាធារណរដ្ឋបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា(AMH) ចុះពិនិត្យ និងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅមណ្ឌលសុខភាពអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ និង

- បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងចូលរួមពិធីផ្សេងៗ ចំនួន៣លើក។

❖ **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា៖

- តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌នៃសាធារណរដ្ឋបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា (AMH) ចុះពិនិត្យ និងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅវត្តសូរិយាពោធិមាស សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និង
- បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងចូលរួមពិធីផ្សេងៗ ចំនួន៤លើក។

- បានធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងសាវតាររបស់ព្រឹទ្ធសភា ប្រគេនព្រះសង្ឃ និងជូនសាស្ត្រាចារ្យ និងសិក្ខាកាមកម្មសិក្សាការីវគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់នៃសាលាភូមិន្ទរដ្ឋបាល។
- បានរៀបចំកម្មវិធីបទបង្ហាញស្តីពី "បទពិសោធន៍នៃការអនុវត្តគោលនយោបាយរបស់សាធារណរដ្ឋប្រជាមានិតចិន" និង"ការចែករំលែកបទពិសោធន៍ និងការអនុវត្តអភិបាលកិច្ចរបស់សាធារណរដ្ឋប្រជាមានិតចិន" និង
- បានទទួលពាក្យបណ្តឹង ចំនួន៧បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធ ចំនួន៥បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន៨បណ្តឹង តម្កល់ទុកមិនចាត់ការ ចំនួន១បណ្តឹង ធ្វើលិខិតរំលឹកជំរុញការដោះស្រាយ ចំនួន៥បណ្តឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធ ចំនួន៥បណ្តឹង ធ្វើកំណត់បង្ហាញគោរពរាយការណ៍ជូន សម្តេចតេជោ ប្រធានព្រឹទ្ធសភា អំពីការឆ្លើយតបលទ្ធផលដោះស្រាយបណ្តឹងរបស់ក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធ ចំនួន៥បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង ចំនួន១៦បណ្តឹង ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន៤បណ្តឹង។

## ៣-មុខងារសហប្រតិបត្តិការអន្តរជាតិ

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា រួមមាន៖**

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** បានទទួលជួបពិភាក្សាការងារ និងអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា និងវិមាន៧មករា ចំនួន៣លើក រួមមាន៖

- **ឯកឧត្តម** Bui Thanh Son ឧបនាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។
- **ឯកឧត្តម** Wilhelm Maximilian Donko ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋអូទ្រីស និង
- **ឯកឧត្តម** TAKAHASHI Fumiaki ប្រធានសមាគមជប៉ុន-កម្ពុជា និងគណៈប្រតិភូជំរុញវិនិយោគជប៉ុនលើកទី៥។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**

- **បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ចំនួន២លើក រួមមាន៖
  - **ឯកឧត្តម វ៉ាង គួរសឹង** សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច នៃសភាប្រឹក្សានយោបាយប្រជាជនចិន នៅវិមានព្រឹទ្ធសភា និង
  - តំណាងក្រុមហ៊ុន Laboratoire Biodrderma និងក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសាធារណរដ្ឋបារាំង ដែលបានមកជួយពិនិត្យ និងព្យាបាលជំងឺ ជូនប្រជាពលរដ្ឋក្រីក្រ និងកុមារដោយឥតគិតថ្លៃ នៅបន្ទប់ទទួលភ្ញៀវរបស់ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា។
- **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
  - បានអញ្ជើញចូលរួមក្នុងពិធីអបអរសាទរខួបលើកទី១០២ នៃការប្រកាសសាធារណរដ្ឋតួកគី នៅសណ្ឋាគារ Rosewood រាជធានីភ្នំពេញ។
  - បានអញ្ជើញចូលរួមពិធីអបអរសាទរខួបលើកទី៧១ នៃការបង្កើតកម្លាំងស្វ័យការពារជប៉ុន នៅនិវេសនដ្ឋានឯកអគ្គរដ្ឋទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា។
  - បានអញ្ជើញរៀបចំកម្មវិធីពិសាអាហារពេលល្ងាចមិត្តភាពជាមួយ **ឯកឧត្តម Wang Wenbin** ឯកអគ្គរដ្ឋទូតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅភោជនីយដ្ឋាន Zhan Liang អគារវឌ្ឍនៈ និង
  - បានអញ្ជើញរៀបចំកម្មវិធីពិសាអាហារពេលថ្ងៃត្រង់មិត្តភាពជាមួយ **លោកជំទាវ អ៊ូយូ ខូចាអេសហ្វេ** ឯកអគ្គរដ្ឋទូតតួកគី ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅភោជនីយដ្ឋាន Topaz។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ទន្សានា អនុប្រធានទី២ព្រឹទ្ធសភា៖**

- **បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា ចំនួន២លើក រួមមាន៖
  - **ឯកឧត្តម UENO Atsushi** ឯកអគ្គរដ្ឋទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា និង **លោកសាស្ត្រាចារ្យ Hosoya Yuichi** អ្នកជំនាញនយោបាយអន្តរជាតិដ៏ល្បី មកពីសកលវិទ្យាល័យ Keio Tokyo និង
  - **លោកស្រី វ៉ាង យ៉ាហ្វួយ** ប្រធានមូលនិធិចិនដើម្បីសន្តិភាព និងការអភិវឌ្ឍ ដើម្បីពិភាក្សាអំពីការលើកកម្ពស់ជីវភាពប្រជាជន តាមរយៈការផ្តល់មូលនិធិជួយវិស័យកសិកម្ម កសិឧស្សាហកម្ម ការអប់រំ សុខាភិបាល និងទេសចរណ៍។
- **បេសកកម្មក្រៅប្រទេស៖** បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា ចូលរួមវេទិកាវប្បធម៌សុខដុមនីយកម្មពិភពលោក ឆ្នាំ២០២៥ ( 2025 Hehe Culture Global Forum ) នៅទីក្រុងថាយចូវ ខេត្តហ្សឺជាំងនៃសាធារណរដ្ឋប្រជាមានិតចិន។

❖ **ឯកឧត្តម ងី ច័ន្ទ្រផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា៖

- បានអញ្ជើញចូលរួមមហាសន្និបាតសហភាពអន្តរសភាលើកទី១៥១ និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស និង
- បានអញ្ជើញចូលរួមកិច្ចប្រជុំសភា លើកទី៣០ នៃសន្និសីទភាគីក្រុបខណ្ឌអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ នៅទីក្រុង Belém ប្រទេសប្រេស៊ីល។

❖ **ឯកឧត្តម យស ផានីត្តា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូទទួលបដិសណ្ឋារកិច្ចស្វាគមន៍គណៈប្រតិភូសភាប្រឹក្សានយោបាយប្រជាជនចិន ដឹកនាំដោយ **ឯកឧត្តម វ៉ាង គួរសឹង** សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការសេដ្ឋកិច្ចនៃសភាប្រឹក្សានយោបាយប្រជាជនចិន CPPCC នៅអាកាសយានដ្ឋានអន្តរជាតិតេជោ។

❖ **ឯកឧត្តមបណ្ឌិត នាង ផាត** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីអបអរសាទរខួបលើកទី៧១ នៃការបង្កើតកងកម្លាំងស្វ័យការពាររបស់ជប៉ុន នៅស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា។

❖ **ឯកឧត្តមបណ្ឌិត ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា៖

- បានអញ្ជើញបំពេញទស្សនកិច្ចការងារ នៅអគ្គលេខាធិការដ្ឋានអាយប៉ា នៅទីក្រុងហ្សាការតា សាធារណរដ្ឋឥណ្ឌូណេស៊ី។
- បានអញ្ជើញចូលរួមពិធីពិសាអាហារការងារជាមួយឯកឧត្តមអគ្គរដ្ឋទូតបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅ À Un Déjeuner À La Résidence De France-1 រាជធានីភ្នំពេញ និង
- បានអញ្ជើញចូលរួមកម្មវិធីអបអរសាទរការចូលជាសមាជិកទី១១ នៃសមាគមប្រជាជាតិអាស៊ី-អាគ្នេយ៍នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ រាជធានីភ្នំពេញ។

❖ **លោកជំទាវបណ្ឌិត ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា៖

- បានអញ្ជើញអមដំណើរ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា ចូលរួមវេទិកាសន្តិភាព ទីក្រុងប៉ារីស ស្តីពី "សម្ព័ន្ធភាពថ្មី ដើម្បីសន្តិភាព ប្រជាជន និងភពផែនដី នៅទីក្រុងប៉ារីស សាធារណរដ្ឋបារាំង និង
- បានអញ្ជើញចូលរួម "វេទិកាកិច្ចសហប្រតិបត្តិការច្បាប់ចិន-អាស៊ាន លើកទី៧" នៅទីក្រុងឆុងឈីង សាធារណរដ្ឋប្រជាមានិតចិន។

❖ **ឯកឧត្តម អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា និង**លោកជំទាវ មុំ សណ្ដាប់** សមាជិកាគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី ការចូលរួមរបស់ប្រជាពលរដ្ឋ និងសភាបើកចំហរ សម្រាប់អភិបាលកិច្ចប្រកបដោយបរិយាបន្ន នៅទីក្រុងវៀងចន្ទន៍ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

❖ **ឯកឧត្តម ង៉ាន់ ចំរើន** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំគណៈកម្មាធិការអេចិន្ត្រៃយ៍នៃសភាតំបន់អាស៊ី (APA) ស្តីពី កិច្ចការសង្គម និងវប្បធម៌ នៅទីក្រុងមូស្គូ សហព័ន្ធរុស្ស៊ី។

❖ **ឯកឧត្តម ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពី "សហគ្រិនភាពរបស់ស្ត្រីប្រាង់កូហ្វូន" នៃគណៈកម្មការកិច្ចការសេដ្ឋកិច្ច សង្គម និងបរិស្ថាននៃសភាប្រើភាសាបារាំង (APF) តាមប្រព័ន្ធនិម្មិត នៅសាលប្រជុំព្រះវិហារ វិមានរដ្ឋសភា និង

❖ **ឯកឧត្តម សេង ម៉ារឌី** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមមហាសន្និបាតលើកទី១៥ និងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ លើកទី៥១ នៃក្រុមប្រឹក្សាសេរីនិយម និងប្រជាធិបតេយ្យអាស៊ី នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖

- បានអញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារ ជាមួយភ្ញៀវអន្តរជាតិ នៅវិមានព្រឹទ្ធសភា និងវិមាន៧មករា ចំនួន៣លើក។
- បានអញ្ជើញចូលរួមអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧១ នៃការបង្កើតកងស្វ័យការពារជប៉ុន នៅនិវេសនដ្ឋានឯកឧត្តមអគ្គរដ្ឋទូតជប៉ុន រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមកម្មវិធីបំពាក់គ្រឿងឥស្សរិយយសខ្ពស់លំដាប់ទី២ របស់រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ដោយ ឯកឧត្តមអគ្គរដ្ឋទូតអាល្លឺម៉ង់ បំពាក់ជូន **ឯកឧត្តមបណ្ឌិត ចែម វីឌ្យ៉ា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា នៅនិវេសនដ្ឋានឯកឧត្តមអគ្គរដ្ឋទូត។
- បានអញ្ជើញចូលរួមកម្មវិធីបើកវេទិកាកិច្ចសហប្រតិបត្តិការច្បាប់ចិន-អាស៊ាន លើកទី៧ នៅទីក្រុងធុងឈីង សាធារណរដ្ឋប្រជាមានិតចិន ដោយក្នុងឱកាសនោះ **ឯកឧត្តមអគ្គលេខាធិការ** បាន៖
    - ថ្លែងសារលិខិតអបអរសាទររបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជូនចំពោះ **ឯកឧត្តម ធិន វិនឈឺង** ក្នុងកម្មវិធីបើកវេទិកា។
    - អញ្ជើញជួបពិភាក្សាការងារ ជាមួយថ្នាក់ដឹកនាំនៃសាធារណរដ្ឋប្រជាមានិតចិន ចំនួន២លើក រួមមាន៖ (១)**លោកសាស្ត្រាចារ្យ** Zhang Xiaojun អគ្គលេខាធិការនៃមជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន និងជាសាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រនយោបាយ និងនីតិសាស្ត្រ និង(២)**ឯកឧត្តម** Wang Hongxiang អនុប្រធានប្រតិបត្តិសមាគមច្បាប់ចិន និង

- អញ្ជើញចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងមជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន ដែលជាការចាប់ផ្តើមដំបូងនៃកិច្ចសហប្រតិបត្តិការលើវិស័យច្បាប់ដែលជាផលប្រយោជន៍រួមរវាងស្ថាប័នទាំងពីរ។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក ប៉ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញទទួលដំណើររបស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ចូលរួមវេទិកាវប្បធម៌សុខដុមនីយកម្មពិភពលោក ឆ្នាំ២០២៥ មាតុភូមិនិវត្តន៍ពីសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិតេជោ។

- បានសហការ និងទាក់ទងជាមួយស្ថានទូតចិន ស្ថានទូតឥណ្ឌា មជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន(CALRC) មជ្ឈមណ្ឌលឯកសារច្បាប់កម្ពុជា សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន មូលនិធិចិនដើម្បីអភិវឌ្ឍន៍ជនបទ (CFRD) បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (CADT) បណ្ណសារដ្ឋានជាតិ-អន្តរជាតិ និងក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ក្នុង-ក្រៅប្រទេសនានា ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ ការស្នើសុំអាហារូបករណ៍ រៀបចំវគ្គបណ្តុះបណ្តាល ការស្វែងរកកៀរគរជំនួយ ព្រមទាំងការរៀបចំកម្មវិធីផ្សេងៗ។

## ៤-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៤.១-សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖
  - បានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមការងារដឹកនាំដោយ **ឯកឧត្តម អ៊ឹម សុខរិទ្ធី** ទីប្រឹក្សាបច្ចេកទេសនៃក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌ ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីបន្តពិភាក្សារៀបចំចងក្រងសៀវភៅ "ប្រវត្តិស្ថាបត្យកម្មអគារនៅវិមានព្រឹទ្ធសភា ចាប់តាំងពីការបង្កើតនៅទសវត្សទី៦០ រហូតដល់ព្រឹទ្ធសភានីតិកាលទី៥" នៅបន្ទប់ឯកឧត្តមអគ្គលេខាធិការ។
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែវិច្ឆិកា និងទិសដៅការងារខែធ្នូ ឆ្នាំ២០២៥ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រួតពិនិត្យបច្ចុប្បន្នភាពគេហទំព័រព្រឹទ្ធសភា នៅបន្ទប់ឯកឧត្តមអគ្គលេខាធិការ និង
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំដំបូងនៃក្រុមការងារស្រាវជ្រាវ និងវិភាគព្រឹត្តិការណ៍តំបន់ និងអន្តរជាតិនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និង**ឯកឧត្តម អោក ប៉ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញអមដំណើរ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានគណៈកម្មការសាងសង់អគារថ្មីនៃព្រឹទ្ធសភា អញ្ជើញចុះពិនិត្យវឌ្ឍនភាពនៃដំណើរការសាងសង់អគារថ្មីនៃព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។

- **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែវិច្ឆិកា និងទិសដៅការងារខែធ្នូ ឆ្នាំ២០២៥ របស់អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងអគ្គនាយកដ្ឋានស្រាវជ្រាវ នៅសាលពិសេសក្រោម វិមានព្រឹទ្ធសភា។

## ៤.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

- បានស្នើសុំបុរេប្រទានថវិកា ចំនួន២បុរេប្រទាន សម្រាប់ចំណាយលើការទិញ X-Ray ថ្មី ម៉ាក Rapisscan 920DX និងខ្លោងទ្វារសុវត្ថិភាព (Walkthrough Gate) ដើម្បីបំពាក់នៅអគារថ្មី និងសម្រាប់ការចំណាយលើបេសកកម្មនៅក្រៅប្រទេសជូន **សម្តេចពិជ័យសេនា ទៀ បាញ់** តំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញទៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។
- បានបង្វែរប្រាក់បង់វិភាគទានហានិភ័យការងារ និងភាគទានថែទាំសុខភាព ជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥។
- បានបង្វែរប្រាក់បៀវត្ស ប្រាក់បំណាច់ ប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិក សមាជិកាព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភាចូលនិវត្តន៍ និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និវត្តជន មន្ត្រីនគរបាលសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានបង្វែរប្រាក់ប្រមុខរដ្ឋស្តីទី ប្រាក់សង្គមកិច្ចថ្នាក់ដឹកនាំព្រឹទ្ធសភា ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺមន្ត្រីរាជការ ប្រាក់៧%នៃប្រាក់បៀវត្សមន្ត្រីរាជការបង់ចូលបេឡាសោធននិវត្តន៍អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងប្រាក់ឧបត្ថម្ភមូលនិធិសង្គមកិច្ចមន្ត្រីរាជការ ប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥ តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៨៧សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន១១៣សំណើ។
- បានដោះស្រាយសំណើផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ ចំនួន៣១សំណើ។
- បានថតចម្លងឯកសារ ចំនួន២,១៤២ច្បាប់ ប្រើប្រាស់ក្រដាសអស់ ចំនួន៣៩,១៤១សន្លឹក។
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្ម នៅតាមបណ្តាភូមិភាគទាំង៨ ចំនួន៧០លើក ស្មើនឹង២០១នាក់។
- បានរៀបចំបោសសម្អាត តុបតែងលម្អសាល ព្រមទាំងផ្តល់សេវាបម្រើភេសជ្ជៈ ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២៧លើក។

- បានទទួលលិខិតចូល ចំនួន៥០៨ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ចំនួន៣៩០ច្បាប់។
- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២១ច្បាប់ ស្មើនឹង៤៥នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៦ច្បាប់។
- បានចុះសួរសុខទុក្ខមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលំហែមាតុភាព នៅរាជធានីភ្នំពេញ ចំនួន១នាក់។
- ការងារកែលម្អសួនច្បារ និងបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា រួមមានៈ
  - បានកាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន១៦លើក។
  - បានតាំងលម្អផ្កា នៅខាងមុខព្រឹទ្ធសភា និងនៅខាងមុខខុទ្ទកាល័យថ្នាក់ដឹកនាំ។
  - បានដាំស្មៅម៉ាឡេ នៅសួនច្បារមុខសាលខាងជើង និងដាំផ្កាអង្កាំមាស នៅសួនច្បារខាងមុខអគារក្រហម ចំនួន១៨០គុម្ព។
  - បានរៀបចំក្រាលគ្រួសក្នុងស៊ុមផ្កា នៅសួនច្បារសាលប្រជុំពេញអង្គ។
  - បានបាញ់ថ្នាំសម្លាប់សត្វល្អិត និងស្មៅតាមសួនច្បារនានា និង
  - បានសម្អាតអនាម័យតាមអគារធ្វើការ និងក្នុងបរិវេណព្រឹទ្ធសភាជាប្រចាំ។
- បានបន្តសម្របសម្រួលការរៀបចំគូរប្លង់រចនាទេសភាពសួនច្បារស្រះត្រី និងសួនច្បារសាលពិសេសវិមានព្រឹទ្ធសភា។
- បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា ប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាៈ
  - មន្ត្រីរាជការក្របខណ្ឌ ចំនួន៧២០នាក់ (ស្រី២៩២) ក្នុងនោះមន្ត្រីរាជការស្ថិតក្នុងភាពទំនេរដោយគ្មានបៀវត្ស ចំនួន១២នាក់, មន្ត្រីរាជការស្ថិតនៅក្រៅក្របខណ្ឌដើម ចំនួន៥នាក់, មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន៤៩៦នាក់ និង
  - បុគ្គលិកជាប់កិច្ចសន្យា ចំនួន៩២នាក់ (ស្រី៣៦នាក់)។
- បានធ្វើសេចក្តីសម្រេច ចំនួន១ច្បាប់ និងលិខិតបង្គាប់ការ ចំនួន២ច្បាប់។
- បានធ្វើតារាងបញ្ជាក់ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ និងវិញ្ញាបនបត្របញ្ជាក់រយៈពេលបំពេញការងាររដ្ឋ ចំនួន១២ច្បាប់។
- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ-កូន) ប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥។
- បានបើកវគ្គបណ្តុះបណ្តាលក្នុងស្ថាប័នព្រឹទ្ធសភា ចំនួន១វគ្គ ស្តីពី ការរៀបចំតាក់តែងលិខិតរដ្ឋបាល និងកិច្ចការលេខាធិការសភា មានសិក្ខាកាមចូលរួម ចំនួន៤៣នាក់។
- បានបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៤នាក់ ចូលរួមវគ្គបណ្តុះបណ្តាលនៅក្រៅស្ថាប័នព្រឹទ្ធសភា ចំនួន២វគ្គ រួមមានៈ

- វគ្គសន្តិសុខសាយប័រស្តីពី ការស្វែងរកចំណុចខ្សោយ និងការជ្រៀតចូលប្រព័ន្ធ នៅវិទ្យាស្ថានអភិបាលកិច្ចឌីជីថល និង
- វគ្គកសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦។

- បានបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២នាក់ ចូលរួមវគ្គបណ្តុះបណ្តាលនៅក្រៅប្រទេស ចំនួន២វគ្គ រួមមាន៖
  - វគ្គ "Fundamental Certificate In Islamic Banking" នៅប្រទេសម៉ាឡេស៊ី និង
  - វគ្គ "ប្រតិបត្តិករវិស័យអប់រំ និងមន្ត្រីរាជការវ័យក្មេង ឆ្នាំ២០២៥" នៅសាធារណរដ្ឋប្រជាមានិតចិន។
- ការងារជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក្នុងបរិវេណវិមានព្រឹទ្ធសភា រួមមាន៖
  - បានប្តូរទទឹក បាញ់ការជញ្ជាំងកញ្ចក់ ជួសជុលពិដាន នៅអគារនាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ និងនាយកដ្ឋានស្រាវជ្រាវថវិកា។
  - បានសហការជាមួយក្រុមការងារសាងសង់អគារថ្មីនៃព្រឹទ្ធសភា ដើម្បីតភ្ជាប់បណ្តាញលូមុខកាត់ 0,៥ម៉ែត្រ ពីអគារថ្មី មកមុខអគារ C ។
  - បានសហការជាមួយក្រុមការងារបណ្តាញលូសាលារាជធានីភ្នំពេញ ដើម្បីបើកការដ្ឋានសាងសង់អាងរំដោះទឹកក្នុងបរិវេណព្រឹទ្ធសភា និង
  - បានជួសជុល និងបានបាញ់ថ្នាំធុងសំរាមថ្មី។
- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្តាញទឹក បណ្តាញអគ្គិសនី ត្រួតពិនិត្យជណ្តើរយន្តកំចាត់សត្វកណ្តៀរ រៀបចំ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិមប្រមូលសម្ភារខូច បិទលេខកូដសម្ភារសារពើភ័ណ្ឌ និងបំពាក់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន៩៩គ្រឿង/លើក។
- បានសម្របសម្រួលការងារការដ្ឋាន និងបានរៀបចំរបាយការណ៍វឌ្ឍនភាពការងារសាងសង់អគារថ្មីនៃព្រឹទ្ធសភា រៀងរាល់ ២សប្តាហ៍ម្តង គោរពជូនថ្នាក់ដឹកនាំព្រឹទ្ធសភា។
- បានបន្តស្រាវជ្រាវ និងរៀបចំសរសេរចងក្រងសៀវភៅអំពីប្រវត្តិ និងការប្រើប្រាស់អគារមួយចំនួននៅវិមានព្រឹទ្ធសភា។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥ ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងផ្ញើជូនក្រសួងស្ថាប័នពាក់ព័ន្ធនានា និង
- បានធ្វើបទបង្ហាញ និងរបាយការណ៍ស្តីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋាន

ព្រឹទ្ធសភា ប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥។

## ៤.៣-ការងារសេវាច្បាប់៖

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស សារាចរណែនាំ សេចក្តីជូនដំណឹង និងលិខិតផ្សេងៗ ចំនួន២០ច្បាប់ ពីក្រសួង និងស្ថាប័ននានា។
- បានរៀបចំឯកសារជំនួយស្មារតីក្នុងកិច្ចដំណើរការនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ជូន៖
    - ថ្នាក់ដឹកនាំព្រឹទ្ធសភា ចំនួន១លើក និង
    - ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១លើក។
- បានធ្វើកំណត់ហេតុពិស្តារ និងកំណត់ហេតុសង្ខេបនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ចំនួន៨លើក។
- បានផ្តល់សេវារដ្ឋបាល បច្ចេកទេស ព័ត៌មាន ពិធីការ ទំនាក់ទំនងការងារ ធ្វើរបាយការណ៍ និងរៀបចំកំណត់បង្ហាញ ឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការទាំង១០ និងក្រុមនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ព្រមទាំងក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២៣៥លើក។
- បានប្រមូលឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល ដែលបានពិនិត្យ ចុះបញ្ជី និងប្រថាប់ត្រាអង្គភាពប្រឆាំងអំពើពុករលួយ ជូនសាមីខ្លួន ឬអ្នកតំណាង ចំនួន២ច្បាប់។
- បានសម្របសម្រួល ចុះបញ្ជី និងបញ្ជូនឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលទទួលការតែងតាំងថ្មី ទៅអង្គភាពប្រឆាំងអំពើពុករលួយ ចំនួន២នាក់ និង
- បានប្រមូល និងតាមដានព័ត៌មានពាក់ព័ន្ធអំពើពុករលួយជាតិ-អន្តរជាតិ ដើម្បីផ្សព្វផ្សាយផ្ទៃក្នុង និងរក្សាទុកជាជំនួយស្មារតីជូនថ្នាក់ដឹកនាំ ចំនួន៥អត្ថបទ។

## ៤.៤-ការងារស្រាវជ្រាវ៖

- បានរៀបចំឯកសារស្រាវជ្រាវ និងឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ ចំនួន៥ច្បាប់។
- បានធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ និងការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ជូនគណៈកម្មការទី២ ព្រឹទ្ធសភា។
- បានចូលរួមធ្វើបទបង្ហាញស្តីពី "បទពិសោធន៍នៃការអនុវត្តគោលនយោបាយរបស់សាធារណរដ្ឋប្រជាមានិតចិន" និង "ការចែករំលែកបទពិសោធន៍ និងការអនុវត្តអភិបាលកិច្ចរបស់សាធារណរដ្ឋប្រជាមានិតចិន នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- បានសិក្សាស្រាវជ្រាវ និងតាមដានវឌ្ឍនភាពនៃការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធតាមវិស័យនានា។
- បានតាមដាន និងចងក្រងឯកសារយុទ្ធសាស្ត្រជាតិស្តីពី ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥។

- បន្តចងក្រងទិន្នន័យលិខិតបទដ្ឋានគតិយុត្តតាមវិស័យរបស់គណៈកម្មការនានា។
- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច ប្រចាំសប្តាហ៍នៃខែវិច្ឆិកា ឆ្នាំ២០២៥ ចំនួន៤ច្បាប់។
- បានបកប្រែ និងសង្ខេបព័ត៌មានសភាបញ្ចូលក្នុងសម្រង់សង្ខេបព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ចំនួន ១៩៧ព័ត៌មាន និង
- បានបញ្ចូលព័ត៌មាន និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (រាជកិច្ចពីលេខ ៤៨-៥២ ឆ្នាំ២០២៤)។

**៤.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា ចំនួន១៥លើក។
- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងបណ្តាញសង្គម ចំនួន១,៥០៥លើក។
- បានបញ្ចូល និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន២៨៨លើក។
- បានអញ្ជើញអ្នកសារព័ត៌មាន ចូលយកព័ត៌មានព្រឹទ្ធសភា និងពិធីផ្សេងៗ ចំនួន៥លើក។
- បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភានៅខាងមុខព្រឹទ្ធសភា ចំនួន ៨លើក។
- បានរៀបចំផលិតទស្សនាវដ្តីព្រឹទ្ធសភា ប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥។
- បានសិក្សាស្រាវជ្រាវ ចងក្រងព្រឹត្តិបត្រ និងផ្សព្វផ្សាយព័ត៌មានស្តីពី បច្ចេកវិទ្យាព័ត៌មាន ចំនួន ១០ចំណងជើង។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ីនធឺណែត ពង្រឹងពង្រីកការផ្គត់ផ្គង់ ថែទាំ និងជួសជុលឧបករណ៍ សម្ភារ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មាន ចំនួន១០៣គ្រឿង/លើក។
- បានរៀបចំប្រព័ន្ធស្ទូឌីយ៉ូ ប្រព័ន្ធកាមេរ៉ា ប្រព័ន្ធប្រជុំនិម្មិត ព្រមទាំងបានរចនាផ្ទាំង Backdrop Background និងបញ្ចាំងផ្ទាំង LED ក្នុងកិច្ចប្រជុំ ជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ និងកម្មវិធីផ្សេងៗ ចំនួន៩៩លើក។
- បានទទួលឯកសារ សៀវភៅច្បាប់ និងសៀវភៅជំនាញផ្សេងៗ ចំនួន៩ក្បាល ព្រមទាំងបានដាក់លេខកូដសៀវភៅ បោះត្រាបិទប័ណ្ណខ្ចី-សងសៀវភៅ ចំនួន១៧ក្បាល។
- បានផ្សព្វផ្សាយឯកសាររបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារច្បាប់ ឯកសារជំនាញ

ផ្សេងៗ និងសៀវភៅជា E-Book តាមគេហទំព័រ www.elibrary.senate.gov.kh ចំនួន ៧,៦៨៣ក្បាល ដែលមានសាធារណជនចូលអាន ចំនួន១,០៣២នាក់ (ដោយគិតចាប់ពីខែមករា ឆ្នាំ២០២០ ដល់ខែវិច្ឆិកា ឆ្នាំ២០២៥) និង

- បានទទួលឯកសារពីអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបានរៀបចំចាត់ចែង តម្កល់រក្សាទុកឯកសារនៅបណ្ណសារដ្ឋាន ដោយបានរៀបចំសៀវភៅព្រឹត្តិបត្រព្រឹទ្ធសភា(ស្នួន) ឆ្នាំ២០១៤ ចំនួន៦៤៨ក្បាល ត្រួតពិនិត្យបញ្ចូលមាតិកាលិខិត និងមាតិកាសំណុំលិខិតទៅក្នុង ប្រព័ន្ធកុំព្យូទ័រ ចំនួន២៨សំណុំ។

## ៤.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និង ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្តែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ចំនួន៤៤លើក។
- បានរៀបចំសារលិខិតជូនពរ លិខិតអបអរសាទរ លិខិតថ្លែងអំណរគុណ និងលិខិតរំលែកទុក្ខ របស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គោរពជូន ឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ ព្រមទាំងថ្នាក់ដឹកនាំតាមក្រសួង ស្ថាប័ននានា ចំនួន ១៤លិខិត។
- បានរៀបចំលិខិតឆ្លើយតប កំណត់ទូត និងឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៤ច្បាប់/លើក។
- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥ ចំនួន ១ច្បាប់។
- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន៩ច្បាប់។
- បានរៀបចំបែបបទស្នើសុំលិខិតឆ្លងដែនការទូតជូនសមាជិកព្រឹទ្ធសភា និងលិខិតឆ្លងដែនផ្លូវការ ជូនទីប្រឹក្សាព្រឹទ្ធសភា និងថ្នាក់ដឹនាំ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៨រូប។
- បានតុបតែងលម្អបំភ្លឺភ្លើងពណ៌ និងចងបដា ពាក្យស្លោក ក្នុងឱកាសនៃពិធីបុណ្យជាតិ នៅខាងមុខ ស្ថាប័នព្រឹទ្ធសភា ចំនួន២លើក និង
- បានតាមដានបញ្ហាជម្លោះព្រំដែនគោករវាងកម្ពុជា-ថៃ និងរាយការណ៍ជូនថ្នាក់ដឹកនាំ។

## ៤.៧-ការងារអគ្គាធិការដ្ឋាន៖

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥ ចំនួន២២លើក។
- បានប្រមូល និងរៀបចំរបាយការណ៍ជាមួយនាយកដ្ឋានផែនការ និងសរុប នាយកដ្ឋានគ្រប់គ្រង បុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ណសារដ្ឋានស្តីពី ការអនុវត្តផែនការការងារ និង គោលនយោបាយនានា របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

- បានរៀបចំរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវា ប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥។
- បានចុះត្រួតពិនិត្យវត្តមានជាក់ស្តែងតាមនាយកដ្ឋាននានា ប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥ ចំនួន២លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមាន ដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមាន ប្រចាំថ្ងៃ ចំនួន៣៤លើក ប្រចាំសប្តាហ៍ ចំនួន៤លើក និងប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥ ដែលគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-ទិសដៅការងារខែធ្នូ ឆ្នាំ២០២៥

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងបើកសម័យប្រជុំលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៥ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ចំនួន៨ច្បាប់ រួមមាន៖
  ១- សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០២៦។
  ២- សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។
  ៣- សេចក្តីព្រាងច្បាប់ស្តីពី កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ។
  ៤- សេចក្តីព្រាងច្បាប់ស្តីពី កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីនស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ។
  ៥- សេចក្តីព្រាងច្បាប់ស្តីពី ពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរីស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។
  ៦- សេចក្តីព្រាងច្បាប់ស្តីពី ពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយស្តីពី ការដឹកជញ្ជូនតាមផ្លូវអាកាសរវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសហភាពអឺរ៉ុប និងរដ្ឋសមាជិករបស់ខ្លួន។
  ៧- សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី៣ស្តីពី ការពង្រីកសិទ្ធិហោះហើរទី៥ រវាងភាគីចុះកិច្ចព្រមព្រៀង ក្រោមកិច្ចព្រមព្រៀងដឹកជញ្ជូនតាមអាកាសរវាងរដ្ឋាភិបាល

នៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន និង

៨- សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១១ និងទី១២ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានស្តីពីសេវាកម្ម។

- ត្រៀមរៀបចំកិច្ចប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ចំនួន៨ច្បាប់។

## ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងចុះបេសកកម្ម ដើម្បីតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។

## ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ពិនិត្យវឌ្ឍនភាពនៃការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ ចូលរួមសិក្ខាសាលា វេទិកា កិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា និង
- ត្រៀមទទួលដំណើរទស្សនកិច្ចរបស់សាធារណជន សិស្ស និងនិស្សិត ដើម្បីសិក្សាឈ្វេងយល់អំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ត្រៀមផ្តល់សេវាការងារការទូតសភា ការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា។
- ត្រៀមរៀបចំដំណើរទស្សនកិច្ចផ្លូវការរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងនាមជាប្រធានព្រឹទ្ធសភា និងជាប្រធានគណបក្សប្រជាជនកម្ពុជា អញ្ជើញទៅសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា និងប្រទេសម៉ាឡេស៊ី។
- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួម៖
    - កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី ថវិកា និងផែនការនៃសភាតំបន់អាស៊ី (APA) នៅទីក្រុងដូហានៃរដ្ឋកាតា និង
    - កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី កិច្ចការនយោបាយនៃសភាតំបន់អាស៊ី(APA) នៅសាធារណរដ្ឋឥស្លាមអ៊ីរ៉ង់។
- បន្តត្រៀមស្រាវជ្រាវ បកប្រែ និងរៀបចំឯកសារជំនួយស្មារតី សុន្ទរកថាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបជាមួយភ្ញៀវអន្តរជាតិ ជំនួបសវនាការ កិច្ចប្រជុំ និងទស្សនកិច្ចនានា។

## ៥- មុខងាររអភិវឌ្ឍន៍ស្ថាប័ន

- ត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពី វិធីសាស្ត្រសរសេរសុន្ទរកថា បទអន្តរាគមន៍ សេចក្តីថ្លែងការណ៍ និងជំនួយស្មារតី។
- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានារួមមាន ការសាងសង់អគារថ្មី ការជួសជុល ថែទាំ កែលម្អបរិស្ថាន អនាម័យ សួនច្បារ ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព។
- បន្តផ្តល់សេវាផ្គត់ផ្គង់សម្ភារ ថវិកា មធ្យោបាយដឹកជញ្ជូន ទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសេវាសំខាន់ៗផ្សេងទៀតជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនឱ្យបានទាន់ពេលវេលា និងល្អប្រសើរ និង
- បន្តចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## III-សេចក្តីសន្និដ្ឋាន

ខែវិច្ឆិកា ស្ថិតក្នុងបរិបទនៃដំណើរឆ្ពោះទៅបញ្ចប់ការងារឆ្នាំ២០២៥ និងការកសាងផែនការសម្រាប់ឆ្នាំ២០២៦។ ក្នុងរយៈពេលនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំយកចិត្តទុកដាក់ខ្ពស់ដើម្បីបញ្ចប់ការងារទៅតាមការគ្រោងទុក។

ចំពោះការងារផ្តល់សេវាលើមុខងារស្នូល អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានភាពមមាញឹកលើការផ្តល់សេវាលើមុខងារតំណាង តាមរយៈការចុះជួបប្រាស្រ័យទាក់ទងជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីជំរុញការអភិវឌ្ឍមូលដ្ឋាន ការបង្កើនគុណភាពការផ្តល់សេវាសាធារណៈ និងការចុះជួយដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋយ៉ាងសស្រាក់សស្រាំ។

ចំពោះការងារការទូតសភាទាំងក្របខណ្ឌស្ថាប័ន និងក្របខណ្ឌអន្តរជាតិ ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានជួបពិភាក្សាការងារ ជួបសវនាការការងារជាមួយភ្ញៀវអន្តរជាតិ និងដំណើរទស្សនកិច្ចការងារ ការចូលរួមកិច្ចប្រជុំ វេទិកា សិក្ខាសាលា ទទួលបានលទ្ធផលគួរជាទីមោទនៈ នាំមកនូវផលប្រយោជន៍សម្រាប់ស្ថាប័ន និងប្រទេសជាតិ។

ក្រៅពីបំពេញការងារក្នុងស្ថាប័ន អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងព្រឹទ្ធសភា បន្តផ្សារភ្ជាប់ជាមួយសកម្មភាពរួមចំណែកលើកទឹកចិត្តចំពោះកងទ័ពនៅសមរភូមិមុខ និងជួយប្រជាជនភៀសសឹក ដែលកំពុងជួបប្រទះនូវការលំបាក។

ថ្ងៃពុធ ១២កើត ខែ មិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ២០២៥

**អគ្គលេខាធិការ**

**ឡាយ សំកុល**